Diploma Programme
Programme du diplôme
Programa del Diploma

# Khmer A: literature – Higher level – Paper 1
# Khmer A : littérature – Niveau supérieur – Épreuve 1
# Khmer A: literatura – Nivel superior – Prueba 1

Wednesday 4 May 2016 (afternoon)
Mercredi 4 mai 2016 (après-midi)
Miércoles 4 de mayo de 2016 (tarde)

2 hours / 2 heures / 2 horas

---

**Instructions to candidates**

- Do not open this examination paper until instructed to do so.
- Write a literary commentary on one passage only.
- The maximum mark for this examination paper is **[20 marks]**.

**Instructions destinées aux candidats**

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire littéraire sur un seul des passages.
- Le nombre maximum de points pour cette épreuve d'examen est de **[20 points]**.

**Instrucciones para los alumnos**

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario literario sobre un solo pasaje.
- La puntuación máxima para esta prueba de examen es **[20 puntos]**.

2216 – 0565



© International Baccalaureate Organization 2016

International Baccalaureate
Baccalauréat International
Bachillerato Internacional

https://xtremepape.rs/

សូមអ្នកសរសេរអត្ថាធិប្បាយបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ៖

**1.**

ម៉ាលីអោនមុខចុះ, មីងភួងផាត់សក់នាងថើរៗ ហើយនិយាយលួងលោមថា៖

- រស់នៅកំសត់កម្រជាមួយគ្នា ទុក្ខសោកអ្វីក៏មីងសន្យាថាជួយរំលែកដែរ... ប្រាប់មីងហ្ន៎ះ ! ក្មួយណ៎ា ប្រាប់មីងមក...

- ខ្ញុំ... និយាយមិនរួចទេមីង...

- ក្មួយស្រី... មីងជឿជាក់ថារឿងក្មួយជារឿងរំជួលចិត្តមែន... មែនទេ ? ឥឡូវមីងហៅក្មួយស្រីពេញៗមាត់ ។ យើងស្រីដូចគ្នា, ទុក្ខស្រីអ្នកក្រគឺមានភាពប្រហាក់ប្រហែលគ្នា, ទុក្ខក្មួយក៏ដូចជាទុក្ខមីង... ឥឡូវក្មួយស្រី និយាយមកចុះកុំរង្កៀសអ្វី... បើមីងអាចជួយបានមីងនឹងជួយក្មួយយកតែបុណ្យទៅចុះ

- ចា៎ស ! ខ្ញុំសុំតែមួយមុខទេ !

- យ៉ាងណា ?

- គឺសុំកុំឱ្យមីងនិយាយរឿងនេះ ឱ្យនរណាដឹងឮតទៅទៀត... ណាមីងណ៎ា !

- អូ ! រឿងតូចប៉ុណ្ណឹងក្មួយកុំខ្វល់ កុំថប់ កុំបារម្ភអ្វី ជឿចិត្តមីងចុះ... មើល !... នាងមានរឿងអ្វី ?

ម៉ាលីស្រីកំសត់ងើបមុខឡើងដកដង្ហើមធំ៖

- ស្រីតូច... ជាកូន... ខ្ញុំ...

នាងភួងភ្ញាក់ស្រឡាំងកាំង ?

- ជាកូននាង ?

- ចា៎...

- អូ !... អីចឹងកាលស៊ីវ៉ាន់ធ្វើការនៅបាត់ដំបងហើយថាបានទាក់ទងនឹងស្រីម្នាក់នោះ គឺក្មួយហ្នឹងហើយ មែនទេ ?

- ចា៎សមីង !... គឺខ្ញុំនេះហើយ ។ សូមមីងកុំនិយាយឱ្យដឹងលឺតទៅទៀត ថាខ្ញុំជាម្តាយស្រីតូចឱ្យសោះ ព្រោះបើ គេដឹងគេបំបែកកូនខ្ញុំពីទ្រូងខ្ញុំទៀតហើយ !

- ពុទ្ធោមាសម្តាយអើយ... យិះ ! លោកយាយម្លិះនេះចិត្តអាក្រក់ណាស់ ទៅលួចកូននាងយកមកធ្វើឱ្យ នាងគ្រាំគ្រាចិត្តណាស់ ។ កាលណោះមីងដឹងរឿងនេះដែរថាស៊ីវ៉ាន់ជាកូនច្បងគ្រួសារនេះបានទៅលបលួច ស្រឡាញ់ស្រីស្រុកស្រែម្នាក់រហូតដល់មានកូនចៅទៀតផង ។ ដំណឹងនេះបានមកដល់លោកតាវិសេសក៏បញ្ជូន ស៊ីវ៉ាន់ទៅស្រុកបារាំងបាត់ ដោយហាមថាកុំមកជាន់ស្រុកខ្មែរទៀត ។ ក្រោយមកលឺថាលោកយាយម្លិះទៅជួល មនុស្សចិត្តអាក្រក់ទៅលួចកូននាងយកមក... យ៉ាងម៉េចមិនដឹងទេ... មីងចាំមិនច្បាស់ ព្រោះរឿងនេះកន្លងមកបួន ឆ្នាំទៅហើយ !

- ចាសមីង គឺនៅថ្ងៃមួយដែលកន្លងមកបួនឆ្នាំហើយ ខ្ញុំបំបៅកូនឱ្យគេងលក់ក្នុងអង្រឹង រួចខ្ញុំដេកយោល កូនដែលលក់ស្កប់ស្កល់ ។ មិនយូរប៉ុន្មាន ខ្ញុំក៏លង់លក់ទៅជាមួយកូនដែរ ។ ខ្ញុំយល់សប្តិឃើញបងស៊ីវ៉ាន់ជាប្តីមក អោបក្រសោបខ្ញុំ... ហើយព្រលឹងខ្ញុំក៏យំក្នុងយល់សប្តិនោះ ដោយរលឹកប្តីខ្លាំងពេក ។ លុះភ្ញាក់ដឹងខ្លួនឡើង ព្រះសុរិយាជ្រៀងជ្រេបន្តិចទៅហើយ ខ្ញុំទាញអង្រឹងយោលកែវជាបុត្រី ។ នែ៎ ! អ្វីក៏ដូច្នេះ ? អង្រឹងទ្រង់ស្រាល ស្ញើក។ ខ្ញុំស្ទុះក្រោកឡើងយ៉ាងរហ័សដូចសត្វដែលព្រានបាញ់ត្រូវ ។ បាត់កូនស្រីខ្ញុំទៅណាហើយ កែវកូនអើយ! ខ្ញុំស្ទុះចេញទៅក្រៅស្រែកហៅរកម្តាយខ្ញុំ តែខាងក្រៅស្ងាត់ឈឹង ។ ម្តាយខ្ញុំទៅផ្សារពុំទាន់មកផង ។ ខ្ញុំនឹកថា ប្រហែលម្តាយខ្ញុំយកទៅមុជទឹកឯស្ទឹង តែ ! គ្មានឃើញអ្វីសោះ ។ ខ្ញុំសួរគេសួរឯងដែលខ្ញុំជួបប្រទះថា “ឃើញអ្នក ណាយកកូនខ្ញុំទេ ?” គេគ្រប់គ្នាឆ្លើយថា “ទេ” ដូចៗគ្នាទាំងអស់ ខ្ញុំពន្យល់ប្រាប់គេវិញពុំទាន់ចប់អស់ សេចក្តីផង ក៏រត់ទៅសួរអ្នកជិតខាងទៀត ។ ខ្ញុំឆ្វេឆ្វាដូចមាន់រកពង ព្រោះអ្នកផងឆ្លើយមកវិញតែពាក្យ“ទេ” ដដែលៗ ។ មិន យូរប៉ុន្មានមនុស្សក្នុងភូមិផ្អើលឆោឡោរកកូនស្រីខ្ញុំ ។ ម្តាយខ្ញុំមកដល់ពីផ្សារវិញក៏ជួយរកទៀត ។ ពេលនោះខ្លួនខ្ញុំ ហាក់ដូចជាមនុស្សវិកលចរិត ខ្ញុំស្រែកទ្រហោយំថា “ឱម្ចាស់ថ្លៃអើយ ! លោកអ្នកណាយកកូនខ្ញុំទៅ ? ពេលខ្ញុំ លង់ក្នុងដំណេកស្រាប់តែភ្ញាក់ឡើងបាត់កូនឈឹង ។ ឱ ! អ្នកណាក៏ចិត្តអាក្រក់ម្ល៉េះ ? លួចអ្វីមិនលួចៗកូនខ្ញុំ ។ កូនស្រីខ្ញុំទើបតែបានមួយខែផង តើនាងបានអីបៅ ? តើគេយកស្ងួនទៅសម្លាប់ចោលឬអ្វី ? កូនៗ ! កូនទើបបាន ឃើញពន្លឺព្រះអាទិត្យមិនបានប៉ុន្មានថ្ងៃផង ស្រាប់តែវិនាសទៅវិញ នាងពុំទាន់ចេះគិតគូរ ពុំទាន់ចេះនិយាយផង ស្រាប់តែគេលួចយកទៅ ។ ឱលោកអ្នកណាអើយធ្វើបាបខ្ញុំយ៉ាងនេះ ? ខ្ញុំស្លាប់ក្នុងពេលនេះប្រាកដហើយ ។ លោកអើយ ! ខ្ញុំគ្មានទ្រព្យធនអ្វីទេ គឺមានតែកូនមួយនេះ” ។ ខ្ញុំដើរបណ្តើរយំបណ្តើរ ពីផ្ទះមួយទៅផ្ទះមួយ រៀបរាប់សព្វគ្រប់អ្នកផងស្តាប់ឮ ហើយក៏ជួយយំគ្រប់ៗគ្នា។

កាណៃល, *កូនអើយឥតម៉ែ* (2001)



https://xtremepape.rs/

**2.**

### ចំណាងបីប្រការ

១.　ពាក្យចាស់បានចារទុកផ្លូវ　រហូតឥឡូវ　នោះត្រូវចាំចង　។
២.　ទទួលយកជាច្បាប់ច្បង　រកសុខម៉ត់ហ្មង　ចំណាងគ្រួសារ　។
៣.　នោះគឺចំណាងសោតណា　មានបីប្រការ　ថាងថាក្បាច់ក្បូន　។
៤.　ចំណាងទីមួយសមសួន　គឺនាងនឹមនួន　ខ្លឹមខ្លួនភរិយា　។
៥.　ចងយើងយ៉ាងជាប់គ្រប់គ្រា　ទោះក្តៅរងា　ឈឺជាម្តេចក្តី　។
៦.　ចិត្តយើងដក់ជាប់ឥតបី　ខ្លាចមានប្រុសថ្មី　ស្រដីឌឺដង　។
៧.　ខ្លាចមានជម្ងឺនោះផង　ទុក្ខសោកកន្លង　សៅហ្មងចំបែង　។
៨.　ជូននឹកចង់លបន្លែង　ខិបខុបខែងរ៉ែង　តាក់តែងបូកប៉ាន់　។
៩.　ជូននឹកឃើញនាងប្រច័ណ្ឌ　ខេរខឹងសាន់រ៉ាន់　ដុកដាន់ឈ្នះចាញ់　។
១០.　ជូននឹកឃើញនាងស្រឡាញ់　ក្ងិកក្ងក់ក្ងេរក្ងាញ់　ឈ្ងុយឆ្ងាញ់ស្នេហា　។
១១.　ជូននឹកឃើញដូចមាតា　ថ្នមថ្នាក់រក្សា　កិច្ចការក្នុងផ្ទះ　។
១២.　ចំណាងនេះរាប់មិនឈ្នះ　រឹតរួតពេញពាស　លាលះមិនបាន　។
១៣.　ចំណាងទីពីរសមសាន្ត　គឺបុត្រកល្យាណ　គ្រប់ប្រាណពេកពិត　។
១៤.　កូនធ្វើឲ្យយើងគន់គិត　រិះរេគំនិត　មូលមិត្តប្រសើរ　។
១៥.　គ្រប់គ្រងអប់រំផ្លូវដើរ　ឲ្យកូនគ្រាន់បើ　ដំណើរល្អជា　។
១៦.　មិនចង់ឃើញកូនវេទនា　ទោះមានក្រគ្រា　ទាមទារតស៊ូ　។
១៧.　លំបាកមិនហ៊ានរអ៊ូ　ក្នុងចិត្តគិតគូរ　ឆាប់យូរតាមហេតុ　។
១៨.　ចង់ឃើញកូនបានឆ្ពល់ឆ្អែត　ខ្ពង់ខ្ពស់ត្រដែត　ត្រសែតត្រសាយ　។
១៩.　ចំណាងនេះចងមិនណាយ　តឹងពេញរាងកាយ　បន្លាយលុះក្ស័យ　។
២០.　ចំណាងមួយទៀតធំក្រៃ　ក៏តឹងអស់ដៃ　ច្រៀវច្រៃគ្រប់គ្រា　។
២១.　គឺភោគសម្បត្តិទ្រព្យា　ឲ្យប្រឹងពុះពារ　ឃាំងឃារលកលៃ　។
២២.　រិះរយឲ្យគង់ប្រពៃ　ខាតបង់ទីទៃ　រំពៃថៃថ្នូន　។
២៣.　ម្យ៉ាងប្រឹងមិនបានដេកពួន　ក្នុងចិត្តមាំមួន　ខំផ្ទួនឲ្យកើន　។
២៤.　ខំរកថែមឲ្យបានច្រើន　ចំរុងចម្រើន　ក្រអើនមិនខ្វាត់　។
២៥.　ភិតភ័យខ្លាចទ្រព្យបង់បាត់　រសាយរសាត់　សូន្យស្ងាត់សោះសល់　។
២៦.　ចំណាងទាំងបីថ្កើងថ្កល់　ដែលមនុស្សខ្វាយខ្វល់　រចល់គ្រប់គ្នា　។
២៧.　ហេតុនេះយើងត្រូវម្នីម្នា　ថែទុកឲ្យជា　ឃ្លាតឃ្លាមិនបាន　។
២៨.　ព្រួតប្រឹងកុំបីខកខាន　រកក្តីសុខសាន្ត　គ្រប់ប្រាណទៅមុខ　៕

ឈាឈៀន, *កំណាប់កំណាព្យ ១* (2013)